មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីថ្លែងការណ៍
# មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាប្រារព្ធទិវានារីអន្តរជាតិ

*រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣*

ទិវានារីអន្តរជាតិ ត្រូវបានប្រារព្ធឡើងនៅថ្ងៃទី០៨ ខែមីនា ជារៀងរាល់ឆ្នាំនៅទូទាំងពិភពលោក ដែលជាការអបអរសាទរចំពោះសមិទ្ធផលនៃការចូលរួមចំណែករបស់ស្ត្រីនៅក្នុងសកម្មភាពសង្គម សេដ្ឋកិច្ច វប្បធម៌ និងនយោបាយ។ ទិវានេះក៏ប្រារព្ធឡើងដើម្បីអំពាវនាវឱ្យមានវិធានការក្នុងការបង្កើនសមភាពយេនឌ័រផងដែរ។ សកម្មភាពគួរឱ្យកត់សម្គាល់ដែលត្រូវបានគេមើលឃើញនៅទូទាំងពិភពលោកនោះ គឺក្រុមនៅតាមមជ្ឈដ្ឋាននានាជួបជុំគ្នាដើម្បីប្រារព្ធអបអរសាទរចំពោះសមិទ្ធផលនៃការចូលរួមរបស់ស្ត្រី ឬក៏ជួបជុំគ្នាដើម្បីសមភាពរបស់ស្ត្រី។ ប្រធានបទសម្រាប់ទិវានារីអន្តរជាតិនៅឆ្នាំ២០២៣ នេះ គឺ «**នវានុវត្តន៍ និងបច្ចេកវិទ្យាឌីជីថលដើម្បីសមភាពយេនឌ័រ**»។

ការប្រារព្ធទិវានារីអន្តរជាតិដ៏សំខាន់នេះ ក៏ជាការលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិរបស់ស្ត្រី និងកៀរគរឱ្យមានការបង្កើនសមភាពយេនឌ័រផងដែរ។ យ៉ាងនេះក្តី គួរឱ្យស្តាយដែលនៅក្នុងទំនៀមទម្លាប់ប្រពៃណីនៅកម្ពុជា នៅតែបន្តមានផ្នត់គំនិតរើសអើងខ្លាំង និងការមិនផ្តល់តម្លៃទៅលើស្ត្រី ហើយបុគ្គលខ្លះនៅតែមានឥរិយាបថប្រមាថក្នុងទម្រង់ផ្សេងៗតាមរយៈកាយវិការ និងពាក្យសម្តីជាដើម ដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ស្ត្រី និងរារាំងដល់ការសម្រេចបានសមភាពយេនឌ័រ។ ជាលទ្ធផល អំពើហិង្សាទាក់ទងនឹងយេនឌ័រនៅតែកើតមានឡើងជាច្រើននៅក្នុងប្រទេស ហើយវប្បធម៌ស្តីបន្ទោសលើជនរងគ្រោះនៅតែបន្តសាបព្រួសនៅក្នុងសង្គមកម្ពុជា។ ការរាតត្បាតនៃជំងឺកូវីដ-១៩ កន្លងមកបានបង្កផលប៉ះពាល់ធ្ងន់ធ្ងរលើស្ត្រីដោយមានការកើនឡើងនូវអំពើហិង្សា ដោយសារការបាត់បង់ការងារ និងបំរាមគោចរ។ ក្នុងពេលវេលាដ៏ប្រឈមទាំងនេះ ចាំបាច់ត្រូវបង្កើនកិច្ចប្រឹងប្រែងដើម្បីដោះស្រាយការរំលោភបំពានលើសិទ្ធិស្ត្រី និងលើកកម្ពស់សមភាពយេនឌ័រនៅកម្ពុជា។

ដើម្បីចូលរួមប្រារព្ធទិនារីអន្តរជាតិ ម.ស.ម.ក នឹងរំលេចនូវសកម្មភាពនៃការចូលរួមរបស់ស្ត្រីកម្ពុជានៅក្នុងសង្គមស៊ីវិល និងការងាររបស់អ្នកការពារសិទ្ធិមនុស្សជាស្ត្រី ព្រមទាំងលើកឡើងនូវបរិយាកាសប្រឈមលើស្ត្រីដែលចូលរួមក្នុងសកម្មភាពសង្គមស៊ីវិលនៅកម្ពុជា តាមរយៈសកម្មភាពមួយចំនួនដូចខាងក្រោម៖

- នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០២៣ ម.ស.ម.ក បានចេញផ្សាយសម្រាប់សាធារណៈជនចូលរួមការប្រកួតរូបថតក្រោមប្រធានបទ «**កម្លាំងស្ត្រី**» សម្រាប់ការចូលរួមប្រារព្ធទិវានារីអន្តរជាតិ នៅលើទំព័រហ្វេសប៊ុករបស់ខ្លួន

- នៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៣ ម.ស.ម.ក នឹងចេញផ្សាយវីដេអូខ្លីអំពីករណីរំលោភបំពានលើសិទ្ធិស្ត្រីក្នុងពេលកូដកម្មនៅណាហ្គាវើលដ៍
- នៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៣ ម.ស.ម.ក នឹងរៀបចំកម្មវិធីដើម្បីប្រារព្ធទិវានារីអន្តរជាតិក្រោមប្រធានបទ «**នវានុវត្តន៍ និងបច្ចេកវិទ្យាឌីជីថលដើម្បីសមភាពយេនឌ័រ**»។ កម្មវិធីនេះនឹងប្រព្រឹត្តទៅនៅការិយាល័យ ម.ស.ម.ក ក្នុងរាជធានីភ្នំពេញ ចាប់ពីវេលាម៉ោង៨.០០នាទីព្រឹក ដល់ម៉ោង១២.០០នាទីថ្ងៃត្រង់ ព្រមទាំងមានការផ្សាយបន្តផ្ទាល់ជាវីដេអូនៅលើទំព័រហ្វេសប៊ុករបស់ ម.ស.ម.ក ផងដែរដើម្បីផ្តល់លទ្ធភាពសម្រាប់ការចូលរួមពីសាធារណជនទូទៅ។ ក្នុងកម្មវិធីនេះក៏នឹងមានការបង្ហាញកម្រងរូបភាពដែលទទួលជ័យលាភីក្នុងការប្រកួតរូបថតក្រោមប្រធានបទ «**កម្លាំងស្ត្រី**»នោះផងដែរ។
- នៅក្នុងខែមីនានេះ កម្មវិធីវិទ្យុសិទ្ធិមនុស្សរបស់ ម.ស.ម.ក នឹងរៀបចំកិច្ចពិភាក្សាវិទ្យុផ្តោតលើប្រធានបទទាក់ទងនឹងបញ្ហារបស់ស្ត្រី។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក សួន យុធ្យា នាយកតស៊ូមតិ ម.ស.ម.ក តាមរយៈអ៊ីម៉ែល: yuthyia@cchrcambodia.org ឬទូរស័ព្ទ: (០) ៨៨ ៨១ ៤២ ៧៨៣៕**

– ចប់ –

**<u>បណ្ណាធិការ៖</u>**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») បង្កើតឡើងក្នុងឆ្នាំ២០០២ ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធដែលធ្វើការដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅព្រះរាជាណាចក្រកម្ពុជា។

ម.ស.ម.ក ជាសមាជិកនៃដៃគូសន្ធនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (IFEX) បណ្តាញសកលដើម្បីសេរីភាពខាងការបញ្ចេញមតិ និងសម្ព័ន្ធពិភពលោកដើម្បីការចូលរួមពលរដ្ឋ (CIVICUS) ។ ម.ស.ម.ក ក៏ជាសមាជិកនៃអង្គការពិភពលោកប្រឆាំងនឹងទារុណកម្ម (OMCT) ជាសមាជិក OECD-Watch ជាសមាជិកនៃបណ្តាញប្រឆាំងទារុណកម្ម អែស អូ អែស និងសម្ព័ន្ធសារព័ត៌មានអាស៊ីអាគ្នេយ៍ (SEAPA) ផងដែរ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ជាជ័យលាភីដែលបានទទួលពានរង្វាន់មូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ស្ថិតក្នុងប្រភេទ «សិទ្ធិ និងសេរីភាព» និងជាជ័យលាភីទទួលពានរង្វាន់ក្នុងឆ្នាំ២០១៣ ផ្នែកទំនាក់ទំនងដើម្បីផ្លាស់ប្តូរសង្គមមកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងការផ្លាស់ប្តូរសង្គមនៅសាកលវិទ្យាល័យឃ្វីនស្លែន ក្នុងទីក្រុងប្រីសបេន ប្រទេសអូស្ត្រាលី៕